DEC.20-11-2001

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២២ ស.សរ

## សេចក្តីសំរេច
## ស្តីពី
## ការបង្កើតគណៈកម្មការចំរុះសំរាប់ដោះស្រាយ ករណី រោងចក្រហ្គោលហ្វាម អ៊ិនធឺប្រាយ គ្លីតធីលីមីធីត

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-យោងស្មារតីសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០០២

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការចំរុះសំរាប់ដោះស្រាយករណីរោងចក្រហ្គោលហ្វាម អ៊ិនធឺប្រាយ គ្លីតធីលីមីធីត ស្ថិតនៅឃុំសិត្បូ ស្រុកស្អាង ខេត្តកណ្តាល ដែលមានសមាសភាពដូចតទៅ :-

| | | |
|---|---|---|
| ១-ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវៈនីតិសម្បទា | ជាប្រធាន |
| ២-ឯកឧត្តម **អ៊ិត ប្រាំង** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | អនុប្រធាន |
| ៣-ឯកឧត្តម **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៤-ឯកឧត្តម **ញាណ ឡេង** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥-ឯកឧត្តម **កឹម ស៊ីថន** | អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៦-ឯកឧត្តម **អ៊ិន នាង** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |

៧-ឯកឧត្តម **សុខ ចិន្តា** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

៨-លោក **ឃឹម បូរ** អភិបាលរងទី១ ខេត្តកណ្តាល សមាជិក

៩-លោក **ឈឹល ចំនួនតារា** មេធាវី នៃអគ្គមេធាវីរាជរដ្ឋាភិបាល សមាជិក

**ប្រការ២** : គណៈកម្មការចំរុះនេះ មានភារកិច្ចដូចតទៅ :-

-ចុះត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវដល់ទីកន្លែង អំពីសភាពការណ៍ មូលហេតុ និងការខូចខាតជាក់ស្តែង នៅក្នុងរោងចក្រហ្គោលហ្វាម អ៊ិនធីប្រាយ ឌីតធីលីមីធីត ដែលបណ្តាលមកពីបាតុកម្មហិង្សា កាលពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០២

-វាយតម្លៃនៃការខូចខាតចលនវត្ថុ អចលនវត្ថុ ផលិតផលកាត់ដេរ និងទ្រព្យសម្បត្តិផ្សេងទៀតរបស់រោងចក្រនេះ

-ធ្វើរបាយការណ៍បូកសរុបអំពីលទ្ធផល នៃការស្រាវជ្រាវ និងលើកវិធានការដោះស្រាយការងារខាងលើ ជូនរាជរដ្ឋាភិបាល ដើម្បីសំរេច ។

**ប្រការ៣** : សមាជិកគណៈកម្មការចំរុះនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាល វិជ្ជាជីវៈ និង យុវនីតិសម្បទា ។

**ប្រការ៤** : គណៈកម្មការចំរុះនេះ មានសិទ្ធិបង្កើតលេខាធិការដ្ឋានមួយជាជំនួយការ ។

**ប្រការ៥** : គណៈកម្មការចំរុះនេះ ត្រូវរំសាយជាស្វ័យប្រវត្តិ ពេលចប់ភារកិច្ច ។

**ប្រការ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ អភិបាលខេត្តកណ្តាល និងឯកឧត្តម ដូចមានចែងក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០២

នាយករដ្ឋមន្ត្រី

**ហ៊ុន សែន**

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៦
- ឯកសារ- កាលប្បវត្តិ